**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៥០៨ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០០៨

**លិខិតចូល**
ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ 2008

# ប្រកាស
# ស្ដីពី
# ការឆ្លងកាត់គយ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស់ / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស / រកម / ០៧០៧ / ០១៧ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## <u>សម្រេច</u>

**ប្រការ ១.-**

ដាក់ឱ្យអនុវត្តនូវនីតិវិធីនៃការឆ្លងកាត់គយ ដែលអនុញ្ញាតឱ្យដឹកទំនិញពីការិយាល័យគយមួយទៅការិយាល័យគយមួយទៀត ក្រោមការត្រួតពិនិត្យរបស់គយ ដោយព្យួរពន្ធ និងអាករនាំចូលស្របតាមបញ្ញត្តិមាត្រា ១៣ និងមាត្រា ២៥ នៃច្បាប់ស្ដីពីគយ ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

**ប្រការ ២.-**

ការឆ្លងកាត់ជាអន្តរជាតិ គឺជាការដឹកជញ្ជូនទំនិញ ពីការិយាល័យគយមាត់ច្រកចូល ចូលទៅក្នុងដែនគយ ឆ្ពោះទៅកាន់ការិយាល័យគយមាត់ច្រកចេញ ចេញទៅក្រៅដែនគយ ហើយការដឹកជញ្ជូនដូចនេះ គឺជាផ្នែកមួយនៃចរាចរទំនិញនេះ ដែលចាប់ផ្តើម និងបញ្ចប់នៅក្រៅដែនគយនៃព្រះរាជាណាចក្រកម្ពុជា ។

ការឆ្លងកាត់ជាតិ មានន័យថា ជាការដឹកជញ្ជូនទំនិញ :

- ពីការិយាល័យគយមាត់ច្រកចូល ឆ្ពោះទៅកាន់ការិយាល័យគយមួយទៀត ឬទីកន្លែងបញ្ចេញទំនិញពីគយដែលមានការអនុញ្ញាត នៅក្នុងដែនគយនៃព្រះរាជាណាចក្រកម្ពុជា
- ពីការិយាល័យគយមួយ ឬទីកន្លែងបញ្ចេញទំនិញពីគយដែលមានការអនុញ្ញាត ទៅការិយាល័យគយមួយនាមាត់ច្រកចេញ
- ពីការិយាល័យគយមួយ ឬទីកន្លែងបញ្ចេញទំនិញពីគយដែលមានការអនុញ្ញាតមួយ ទៅការិយាល័យគយមួយទៀត ឬទីកន្លែងបញ្ចេញទំនិញពីគយដែលមានការអនុញ្ញាតផ្សេងទៀត នៅក្នុងដែនគយ ។

**ប្រការ ៣.-**

ទំនិញ និងមធ្យោបាយដឹកជញ្ជូនឆ្លងកាត់នឹងមិនត្រូវជាកម្មវត្ថុនៃការជាប់ពន្ធ និងអាករនាំចូលទេ ប៉ុន្តែអាចជាកម្មវត្ថុនៃការជាប់បន្ទុក ឬកម្រៃផ្សេងៗពាក់ព័ន្ធទៅនឹងថ្លៃចំណាយ សម្រាប់ចាត់ចែងប្រតិបត្តិការឆ្លងកាត់នេះ ដែលនឹងកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៤.-**

ក្នុងគោលបំណងដើម្បីធានានូវប្រសិទ្ធភាពនៃការត្រួតពិនិត្យរបស់គយចំពោះប្រតិបត្តិការឆ្លងកាត់គយ និងដើម្បីជម្រុញកិច្ចសម្រួលពាណិជ្ជកម្ម នាយកទីចាត់ការគយ និងរដ្ឋាករអាចកំណត់លក្ខខណ្ឌនានាពាក់ព័ន្ធនឹងប្រតិបត្តិការឆ្លងកាត់ដោយអនុលោមតាមកាតព្វកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ក្រោមបញ្ញត្តិនៃកិច្ចព្រមព្រៀងអន្តរជាតិនានាដែលពាក់ព័ន្ធនិងការអនុវត្តតាមស្តង់ដារល្អបំផុតជាអន្តរជាតិ។

លក្ខខណ្ឌនានា ដែលអាចនឹងត្រូវកំណត់ដោយ នាយកទីចាត់ការគយ និងរដ្ឋាករួមមាន ៖

- ការកំណត់នូវប្រតិបត្តិករឆ្លងកាត់ដែលមានការអនុញ្ញាត រួមទាំងសិទ្ធិក្នុងការបញ្ឈប់ជាបណ្តោះអាសន្ន ឬជារៀងរហូតនូវការប្រើប្រាស់នីតិវិធីឆ្លងកាត់ចំពោះបុគ្គលណាដែលបានប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីគយ ឬបទបញ្ញត្តិពាក់ព័ន្ធនានាជាធរមាន

- នីតិវិធីប្រតិបត្តិការលម្អិតរួមមាន តម្រូវការឯកសារ របៀបប្រកាស និងការដាក់កម្រិតកំណត់ផ្សេងទៀត ពាក់ព័ន្ធនឹងនីតិវិធីនាការិយាល័យគយមាត់ច្រកចូល ការិយាល័យគយមាត់ច្រកចេញ និងការកំណត់តម្រាយផ្លូវស្របច្បាប់ និងរយៈពេលដឹកជញ្ជូនក្រោមរបបគយឆ្លងកាត់

- នីតិវិធីត្រួតពិនិត្យរបស់គយ ព្រមទាំងតម្រូវការបិទត្រា ឬសៀលគយលើមធ្យោបាយដឹកជញ្ជូន ឬកុងតេន័រ

- នីតិវិធីដែលត្រូវអនុវត្តក្នុងករណីមានការបាត់បង់ឬការធ្វើឱ្យខូចខាតនូវទំនិញឆ្លងកាត់ ការដាច់ រហែកត្រា ឬសៀលគយ ព្រមទាំងហេតុការណ៍ ឬគ្រោះថ្នាក់ដទៃទៀត ដែលអាចប៉ះពាល់ដល់លទ្ធភាពនៃការអនុវត្តនូវកាតព្វកិច្ចនានារបស់ប្រតិបត្តិករឆ្លងកាត់

- ប្រភេទមធ្យោបាយដឹកជញ្ជូន និងកុងតេន័រផ្ទុកទំនិញដែលអាចធានានូវស្តង់ដារសន្តិសុខទំនិញឆ្លងកាត់

- តម្រូវការតម្កល់និមុត្តិធានា តាមបញ្ញត្តិនៃប្រកាសស្តីពីនិមុត្តិធានា ។

**ប្រការ ៥.-**

បទល្មើសពាក់ព័ន្ធនឹងប្រតិបត្តិការឆ្លងកាត់ ត្រូវដោះស្រាយដោយអនុលោមតាមបញ្ញត្តិនៃច្បាប់ស្តីពីគយ ព្រមទាំងច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធជាធរមានផ្សេងទៀតនៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៦.-**

លើកលែងករណីដូចមានចែងក្នុងបញ្ញត្តិប្រការ ៧ នៃប្រកាសនេះ មានតែទំនិញឆ្លងកាត់ដែលដឹកជញ្ជូនតាមកុងតេន័រដូចមានចែងក្នុងបញ្ញត្តិកថាខណ្ឌទី ២ នៃប្រការនេះ ឬមធ្យោបាយដឹកជញ្ជូនដែលទទួលបានការអនុញ្ញាតពីទីចាត់ការគយ និងរដ្ឋាករប៉ុណ្ណោះ ដែលអាចដឹកជញ្ជូនទំនិញក្រោមរបបគយឆ្លងកាត់បាន ។

សម្រាប់គោលបំណងនៃប្រកាសនេះ កុងតេន័រមានន័យថា ជាឧបករណ៍ ឬបរិក្ខារដឹកជញ្ជូនដែល ៖

- ជាមធ្យោបាយផ្ទុកទំនិញដែលអាចផ្តល់លទ្ធភាពឱ្យបិទត្រា ឬសៀល សុវត្ថិភាពគយបាន

- មានលក្ខណៈអចិន្ត្រៃយ៍ និងរឹងមាំសម្រាប់ការប្រើប្រាស់ច្រើនដង

- បង្កើតឡើងជាពិសេសដើម្បីបង្កការងាយស្រួលដល់ការដឹកជញ្ជូនទំនិញ ដោយមធ្យោបាយដឹកជញ្ជូនមួយ ឬច្រើនប្រភេទ ដោយមិនចាំបាច់ផ្ទេរទំនិញឡើង ឬចុះដដែល ៗ

- បង្កើតឡើងដើម្បីឱ្យមានភាពងាយស្រួលសម្រាប់ការគ្រប់គ្រង និងលើក ដាក់ ជាពិសេសនៅពេលផ្ទេរពីមធ្យោបាយដឹកជញ្ជូនមួយ ទៅមធ្យោបាយដឹកជញ្ជូន មួយទៀត

- បង្កើតឡើងដើម្បីឱ្យមានភាពងាយស្រួលដល់ការផ្ទុក ឬផ្ទេរទំនិញ

- មានមាឌខាងក្នុងយ៉ាងតិចបំផុតមួយម៉ែត្រគូប ។

មធ្យោបាយដឹកជញ្ជូន ដែលទទួលបានការអនុញ្ញាតសម្រាប់របបគយ ឆ្លងកាត់ត្រូវរៀបចំ និងបំពាក់បរិក្ខារដែល ៖

-អាចបិទត្រា ឬសៀលគយបានដោយងាយ និងមានប្រសិទ្ធភាព

-គ្មានទំនិញណាអាចយកចេញ ឬដាក់ចូលក្នុងផ្នែកដែលបានគឹបសៀល ហើយនៃមធ្យោបាយដឹកជញ្ជូន ដោយពុំមានបន្សល់ឱ្យឃើញនូវស្លាកស្នាមនៃការ ខូចខាត ឬដោយពុំមានការផ្តាច់ត្រា ឬសៀលគយឡើយ ។

- ពុំមានកន្លែងចន្លោះទំនេរដែលអាចលាក់ទំនិញបាន

- កន្លែងដែលអាចផ្ទុកទំនិញ អាចត្រូវបានត្រួតពិនិត្យយ៉ាងងាយស្រួល ដោយមន្ត្រីគយមានសមត្ថកិច្ច ។

ទីចាត់ការគយ និងរដ្ឋាករត្រូវកំណត់នូវមធ្យោបាយដឹកជញ្ជូន និង កុងតេន័រដែលមានសុវត្ថិភាព សម្រាប់គោលបំណងនៃការត្រួតពិនិត្យប្រតិបត្តិការ ឆ្លងកាត់គយប្រកបដោយប្រសិទ្ធភាព ។

Ra

**ប្រការ ៧.-**

ទំនិញធ្ងន់ឬទំនិញចាក់ជា ដែលដោយសារតែទម្ងន់ ទំហំ ឬសភាពរបស់វា ហើយជាធម្មតាមិនអាចផ្ទុកក្នុងកុងតេន័របិទជិតបាន អាចត្រូវបានអនុញ្ញាតដោយរដ្ឋបាលគយឱ្យដឹកជញ្ជូនដោយយានយន្ត ឬកុងតេន័រដែលពុំមានបិទត្រា ឬសៀលគយបាន ប្រសិនបើទំនិញនោះអាចត្រូវបានកំណត់អត្តសញ្ញាណ ដោយងាយស្រួលតាមរយៈការបរិយាយក្នុងឯកសារយោងដែលបានផ្តល់ឱ្យគយដូចជា បញ្ជីវេចខ្ចប់ រូបថត ឬគំនូសព្រាងជាដើម ។

មន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ច ត្រូវចាត់វិធានសមស្របដើម្បីឃ្លាំមើល និងបង្ការមិនឱ្យមានការផ្លាស់ប្តូរ ការដកចេញ ឬការបន្ថែមទំនិញ ។

**ប្រការ ៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៩.-**

ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ទីចាត់ការគយ និងរដ្ឋាករ
- ដូចប្រការ ៨
- សភាពាណិជ្ជកម្មកម្ពុជា "ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ